ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃ អង្គារ ៣ រោច ខែ ភទ្របទ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២២

# សេចក្ដីប្រកាសព័ត៌មាន

## អង្គប្រជុំក្រុមការងារ "ឃ" ផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច រវាងរាជរដ្ឋាភិបាលជាមួយវិស័យឯកជន

នាព្រឹកថ្ងៃទី ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២២ តាមរយៈប្រព័ន្ធវីដេអូ (Video Conference), ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាសហប្រធានក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និង អភិបាលកិច្ច "**ក្រុម ឃ**" នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន រួមជាមួយនឹងលោក អានូដ ដាក (Arnaud Darc) សហប្រធាន "**ក្រុម ឃ**" (ខាងផ្នែកឯកជន) ដឹកនាំកិច្ចប្រជុំ "**ក្រុម ឃ**" ក្នុងគោលបំណងពិនិត្យ និង បន្តដោះស្រាយបញ្ហា ក្ដីកង្វល់ និង សំណូមពររបស់វិស័យឯកជន ដោយមានការចូលរួមពីសហសេវិកទាំងផ្នែករាជរដ្ឋាភិបាល និង វិស័យឯកជន ក្នុងគោលដៅជំរុញសកម្មភាពវិនិយោគ និង ធុរកិច្ច ក្នុងបរិការណ៍ប្រទេសកម្ពុជាបើកសង្គម សេដ្ឋកិច្ចឡើងវិញ ក្រោយពីមានភាពរអាក់រអួលអស់រយៈពេល ២ ឆ្នាំ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ និង កម្ពុជាមានភាពស៊ាំសហគមន៍ពេញលេញ ក្នុងការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានអនុញ្ញាតឱ្យមានការពិភាក្សាដោយបើកចំហររវាងភាគីវិស័យឯកជន និង រាជរដ្ឋាភិបាល លើបញ្ហាប្រឈម កង្វល់ និង សំណូមពររបស់វិស័យឯកជន ដើម្បីស្វែងរកដំណោះស្រាយសមស្រប និង យុត្តិធម៌ ព្រមទាំងលើកកម្ពស់បរិយាកាសវិនិយោគ និង ធុរកិច្ច ប្រកបដោយប្រកួតប្រជែងស្មើភាពគ្នា និង មានតម្លាភាព ព្រមទាំងរក្សាបាននូវការអនុវត្តច្បាប់ និង បទប្បញ្ញត្តិ ដែលមានជាធរមាន ។ កិច្ចប្រជុំនេះបានពិភាក្សាលើរបៀបវារៈចំនួន ៥ រួមមាន : *១.* ពន្ធលើស្លាកសញ្ញា និងពន្ធលើផ្ទាំងពាណិជ្ជកម្ម, *២.* ពាណិជ្ជកម្មខុសច្បាប់ (ដែលសំដៅលើបារីខុសច្បាប់ និង ក្លែង

ក្លាយ), ៣. ពន្ធលើការផ្ទេរភាគហ៊ុន, ៤. សិទ្ធិផ្តាច់មុខ និងការនាំចូលយានជំនិះម៉ូដែលចុងក្រោយបំផុត ខណៈអ្នកផ្សេងទៀតកំពុងកាន់សិទ្ធិផ្តាច់មុខ និង ៥. អាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ នៅក្នុងវិស័យហិរញ្ញវត្ថុ ។

ជាលទ្ធផល, កិច្ចប្រជុំបានដោះស្រាយបញ្ហា និង ធ្វើការបំភ្លឺនានា ដែលវិស័យឯកជនបានលើកឡើង ដោយបានដាក់ចេញនូវវិធានការ យន្តការ និង ការងារបន្ទាប់ សម្រាប់ក្រសួង-ស្ថាប័នតាមសមត្ថកិច្ចរៀងខ្លួនៗ បន្តបំពេញភារកិច្ច និង សម្រេចឱ្យបាន ដែលឆ្លើយតបនឹងសំណូមពររបស់វិស័យឯកជន ពិសេសសម្រាប់ការរៀបចំកិច្ចប្រជុំលើកក្រោយទៀត ។ ផ្អែកតាមនេះ វិស័យឯកជនក៏បានឯកភាព និង បន្តសហការចូលរួមអនុវត្ត ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានសំដែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា អស់លោក លោកស្រី ជាសហសេវិកទាំងអស់ ទាំងខាងផ្នែករាជរដ្ឋាភិបាល ទាំងផ្នែកដៃគូវិស័យឯកជន និង បានជូនពរឱ្យទទួលបានសុខភាពល្អ ជ័យជំនះគ្រប់ភារកិច្ច និង ទទួលបានសុភមង្គលក្នុងក្រុមគ្រួសារ ។